ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH WATER SUPPLY AUTHORITY
រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
"រ.ទ.ស.ភ"

លេខ ២២៤ ស.ជ.ល

ភ្នំពេញ, ថ្ងៃទី០៣ ខែ តុលា ឆ្នាំ ២០១៧

## លិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា
## ផ្គត់ផ្គង់រថយន្ត PICK UP DOUBLE CABIN ចំនួន៨គ្រឿង

ខ្ញុំមានកិត្តិយសជម្រាបលោកប្រធានក្រុមហ៊ុន **អ អិម អេ (ខេមបូឌា)** ថា ៖ ក្រោយពីការវាយតម្លៃលើឯកសារដាក់ដេញថ្លៃពីគ្រប់ក្រុមហ៊ុន ដែលបានបើកជាសាធារណៈកាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ ដើម្បីផ្គត់ផ្គង់រថយន្ត PICK UP DOUBLE CABIN ចំនួន៨គ្រឿង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានសម្រេចប្រគល់កិច្ចសន្យាជូនទៅក្រុមហ៊ុន **អ អិម អេ (ខេមបូឌា)** ក្នុងតម្លៃកិច្ចសន្យាចំនួន **១,១៥០,២០០,០០០រៀល (មួយប៊ីលានមួយរយហាសិបលានពីររយពាន់រៀលគត់)**។

អាស្រ័យហេតុនេះ សូមលោកប្រធានពិនិត្យ និងចុះហត្ថលេខាលើកិច្ចសន្យា ដែលបានជូនភ្ជាប់ រួចប្រគល់មករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយមានភ្ជាប់មកជាមួយនូវប្រាក់កក់ធានាលើការអនុវត្តកិច្ចសន្យា (Performance Security) ដោយអនុលោមទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា ក្នុងអំឡុងពេលមិនលើសពី១៥ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យានេះ។

សូមលោកប្រធានទទួលយកនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ជ.អគ្គនាយក**
អគ្គនាយករង

**បណ្ឌិត ជា វិសុទ្ធ**

ចម្លងជូន៖
-ក្រុមហ៊ុន មីតស៊ុយ (ខេមបូឌា)
-ក្រុមហ៊ុន អេច ជី ប៊ី អូតូ

អាសយដ្ឋាន: លេខ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទ: ៨៥៥(២៣) ៧២៤ ០៤៦ Email: admin@ppwsa.com.kh